# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# <u>លក្ខន្តិកៈ</u>
## របស់
## សមាគមអតីតនិស្សិតខ្មែរពីប្រទេសជប៉ុន

## <u>ជំពូកទី ១</u>
## ការបង្កើត ឈ្មោះ ទីស្នាក់ការ គោលបំណង រយៈពេល និងផ្លាកសញ្ញា

**មាត្រា ១.- ការបង្កើត និងឈ្មោះ**

និស្សិតខ្មែរដែលបានបញ្ចប់ការសិក្សាមកពីប្រទេសជប៉ុន បានព្រមព្រៀងគ្នាបង្កើតសមាគមក្រៅរដ្ឋាភិបាលមួយស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលមានឈ្មោះថា "**សមាគមអតីតនិស្សិតខ្មែរពីប្រទេសជប៉ុន**" ហៅកាត់ថា "**ស.អ.ន.ខ.ជ**" និងឈ្មោះជាភាសាអង់គ្លេស "**JAPAN ALUMNI OF CAMBODIA**" ហៅកាត់ថា"**JAC**"។

ស.អ.ន.ខ.ជ ជាសមាគមក្រៅរដ្ឋាភិបាលមិនធ្វើនយោបាយមិនស្វែងរកផលចំណេញជាលក្ខណៈឯកជនឡើយ។

**មាត្រា ២.- ទីស្នាក់ការ**

ស.អ.ន.ខ.ជ មានទីស្នាក់ការនៅផ្ទះលេខ៥៩D ផ្លូវលេខ២៣០ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ទីស្នាក់ការនេះអាចផ្លាស់ប្តូរបានតាមការសម្រេចរបស់គណៈកម្មាធិការនាយក និងត្រូវជូនដំណឹងដល់ក្រសួងមានសមត្ថកិច្ច ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយ។ ស.អ.ន.ខ.ជ អាចបើកសាខានៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៣.- គោលបំណង**

ស.អ.ន.ខ.ជ មានគោលបំណង ៖

- រឹតចំណងសាមគ្គីភាពរវាងនិស្សិតខ្មែរទាំងអស់ដែលធ្លាប់បានសិក្សានៅប្រទេសជប៉ុន។
- ផ្លាស់ប្តូរព័ត៌មាន និងមតិយោបល់ដែលអាចមានប្រយោជន៍ដល់សមាជិក សមាជិកា។
- បណ្តុះបណ្តាលនូវគំនិតថ្លៃថ្នូរ ថ្នៃប្រឌិត និងវិទ្យាសាស្ត្រជឿនលឿនក្នុងចំណោមសមាជិក សមាជិកា។
- សិក្សាស្រាវជ្រាវ និងចែករំលែកព័ត៌មានអាហារូបករណ៍ដល់និស្សិតខ្មែរដែលមានបំណងចង់បន្តការសិក្សានៅប្រទេសជប៉ុន។

- ចងក្រង និងបោះពុម្ពផ្សាយនូវនិក្ខេបបទ អត្ថបទ និងទម្រង់នៃការសរសេរអត្ថបទស្រាវជ្រាវដល់សមាជិក សមាជិកាក៏ដូចជានិស្សិតខ្មែរទូទៅ។
- ជួយដោះស្រាយបញ្ហា ឬទុក្ខធុរៈរបស់សមាជិក សមាជិកាតាមលទ្ធភាពដែលអាចធ្វើបាន។
- ធ្វើសហប្រតិបត្តិការជាមួយសមាគមនានាទាំងក្នុង និងក្រៅប្រទេសជាពិសេសជាមួយសមាគមនិស្សិតខ្មែរនៅប្រទេសជប៉ុន និងសហគមន៍ ព្រមទាំងសមាគមជប៉ុននៅកម្ពុជាសំដៅកៀគរជំនួយ និងផលប្រយោជន៍ផ្សេងៗដល់សមាជិក សមាជិកា និងប្រទេសជាតិ។
- ជួយផ្សព្វផ្សាយសក្តានុពលសេដ្ឋកិច្ច និងទេសចរណ៍កម្ពុជាសំដៅទាក់ទាញអ្នកទេសចរណ៍ និងវិនិយោគិនជប៉ុនមកកម្ពុជា។
- ជាស្ពានចម្លងវប្បធម៌ ប្រពៃណី និងទំនៀមទំលាប់ល្អៗនៃប្រទេសកម្ពុជា និងជប៉ុន។
- ធ្វើសកម្មភាពទាំងឡាយណាដែលមានប្រយោជន៍ និងលើកតម្កើងកិត្តិយស ស.អ.ន.ខ.ជ និងប្រទេសជាតិ។

**មាត្រា ៤.- រយៈពេល**

ស.អ.ន.ខ.ជ បង្កើតឡើងសម្រាប់រយៈពេលគ្មានកំណត់។

**មាត្រា ៥.- ផ្លាកសញ្ញា**

ផ្លាកសញ្ញារបស់ ស.អ.ន.ខ.ជ មានរាងមូល និងលក្ខណៈសម្គាល់ដូចខាងក្រោមៈ

- សញ្ញាចាប់ដៃនៅកណ្តាលអមដោយរូបសញ្ញាកួរស្រូវពណ៌មាសនៅខាងឆ្វេង និងស្លឹកអូលីវពណ៌បៃតងនៅខាងស្តាំ។
- ផ្នែកខាងលើនៃកួរស្រូវ និងស្លឹកអូលីវត្រូវបានភ្ជាប់ដោយអក្សរ "សមាគមអតីតនិស្សិតខ្មែរពីប្រទេសជប៉ុន" រីឯផ្នែកខាងក្រោមនៃកួរស្រូវ និងស្លឹកអូលីវត្រូវបានភ្ជាប់ដោយទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុន ហើយផ្នែកខាងក្រោមនៃទង់ជាតិប្រទេសទាំងពីរត្រូវបានភ្ជាប់គ្នាដោយអក្សរ "JAC"។ រីឯផ្នែកខាងលើនៃទង់ជាតិប្រទេសទាំងពីរត្រូវបានភ្ជាប់គ្នាដោយអក្សរ "ស.អ.ន.ខ.ជ"។
- នៅខាងលើសញ្ញាចាប់ដៃមានរូបស្រមោលមួកនិស្សិត។
- នៅខាងក្រោមសញ្ញាចាប់ដៃមានអក្សរជាភាសាអង់គ្លេស "Japan Alumni of Cambodia"។

ស្លាកសញ្ញារបស់ ស.អ.ន.ខ.ជ ជាឧបសម្ព័ន្ធនៃលក្ខន្តិកៈ។

## <u>ជំពូកទី ២</u>

## សមាជិកភាព

**មាត្រា ៦.- សមាជិក សមាជិកា**

ស.អ.ន.ខ.ជ មានសមាជិក សមាជិកាស្ថាបនិក កិត្តិយស សកម្ម និងធម្មតា។

**ក-** សមាជិក សមាជិកាស្ថាបនិក គឺជាសមាជិក សមាជិកាសកម្មដែលបានផ្តួចផ្តើមបង្កើត ស.អ.ន.ខ.ជមុនដំបូង។

**ខ**- សមាជិក សមាជិកាកិត្តិយស គឺជាសមាជិក សមាជិកាដែលបានជួយជ្រោមជ្រែងសកម្មភាពរបស់ស.អ.ន.ខ.ជនិងព្រមទទួលយកសមាជិកភាពនេះ។

**គ**- សមាជិក សមាជិកាសកម្ម គឺជាសមាជិក សមាជិកាដែលបាន ឬកំពុងបំពេញតួនាទីក្នុងគណៈកម្មាធិការនាយករបស់សមាគម។

**ឃ**- សមាជិក សមាជិកាធម្មតា គឺជាសមាជិក សមាជិកាដែលមិនស្ថិតនៅក្នុងប្រភេទសមាជិកភាពទាំងបីខាងលើ និងមានឈ្មោះនៅក្នុងបញ្ជីទំនាក់ទំនងរបស់ ស.អ.ន.ខ.ជ។

**មាត្រា ៧.- ការសុំចូលសមាជិកភាព**

អតីតនិស្សិតខ្មែរគ្រប់រូបដែលបានទៅសិក្សានៅប្រទេសជប៉ុនចាប់ពីរយៈពេល ០៦ខែឡើងអាចក្លាយជាសមាជិក សមាជិការបស់ស.អ.ន.ខ.ជ។ ដើម្បីទទួលបានសមាជិកភាពនេះ អតីតនិស្សិតត្រូវដាក់ពាក្យសុំសមាជិកភាព ឬផ្ញើសារអេឡិចត្រូនិកមកគណៈកម្មាធិការនាយក។

សមាជិកភាពកិត្តិយសនឹងត្រូវបានផ្តល់ជូនដោយការអនុម័តរបស់គណៈកម្មាធិការនាយក។

**មាត្រា ៨.- ការបាត់បង់សមាជិកភាព**

សមាជិក សមាជិកានៃ ស.អ.ន.ខ.ជ នឹងបាត់បង់សមាជិកភាពរបស់ខ្លួនក្នុងករណីសមាជិក សមាជិការូបនោះ៖

- សុំលាលែង
- ទទួលមរណភាព
- ត្រូវបានលុបឈ្មោះចេញពីបញ្ជីសមាជិកភាពតាមការសម្រេចសម្លេងភាគច្រើន (៥០ភាគរយបូក១) នៃចំនួនសមាជិក សមាជិកាដែលមានវត្តមាននៅក្នុងអង្គសន្និបាត។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**មាត្រា ៩.-** ស.អ.ន.ខ.ជ ដឹកនាំដោយគណៈកម្មាធិការនាយកមួយដែលមានសមាសភាពដូចតទៅ៖

| | |
|---|---|
| - ប្រធាន | ០១ (មួយ) រូប |
| - អនុប្រធាន | មួយចំនួនតាមការចាំបាច់ |
| - អគ្គលេខាធិការ | ០១ (មួយ) រូប |
| - អគ្គលេខាធិការរង | មួយចំនួនតាមការចាំបាច់ |
| - ផ្នែករដ្ឋបាល | |
| - ផ្នែកហិរញ្ញវត្ថុ | |
| - ផ្នែកទំនាក់ទំនង និងវប្បធម៌ | |
| - ផ្នែកនិពន្ធ | |

- ផ្នែកព័ត៌មានវិទ្យា

ផ្នែកនីមួយៗដឹកនាំដោយប្រធាន ១ (មួយ) រូប និងអនុប្រធានមួយចំនួនតាមការចាំបាច់។

រចនាសម្ព័ន្ធនៃគណៈកម្មាធិការនាយកអាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង និងជាឆន្ទានុសិទ្ធិរបស់ប្រធានដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយអង្គសន្និបាត។

**មាត្រា ១០**.- ស.អ.ន.ខ.ជ អាចមានទីប្រឹក្សាមួយចំនួនតាមការចាំបាច់។ ប្រធានសមាគមដែលចប់អណត្តិត្រូវបានផ្តល់តួនាទីជាទីប្រឹក្សានៃសមាគមដោយស្វ័យប្រវត្តិលើកលែងតែសមីខ្លួនបដិសេធ។

**មាត្រា ១១**.- ស.អ.ន.ខ.ជ ត្រូវមានសវនករឯករាជ្យ ១ (មួយ) រូប ដែលជ្រើសរើសដោយការបោះឆ្នោតក្នុងអង្គសន្និបាតរបស់ ស.អ.ន.ខ.ជ ដូចនីតិវិធីនៃការជ្រើសរើសប្រធានដែរ។

**មាត្រា ១២**.- ប្រធានគណៈកម្មាធិការនាយកនៃ ស.អ.ន.ខ.ជ ជាប្រធាន ស.អ.ន.ខ.ជ។

**មាត្រា ១៣**.- ប្រធានគណៈកម្មាធិការនាយកនៃ ស.អ.ន.ខ.ជ ត្រូវជ្រើសរើសឡើងសម្រាប់អាណត្តិ ៣ (បី) ឆ្នាំ។

**មាត្រា ១៤**.- ការបោះឆ្នោតជ្រើសរើសប្រធានគណៈកម្មាធិការនាយក ត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតជាសម្ងាត់ដោយសម្លេងភាគច្រើននៃសមាជិក សមាជិកាដែលមានវត្តមាននៅក្នុងអង្គសន្និបាត។

ក្នុងករណីដែលបេក្ខជន ឬបេក្ខនារីទទួលបានសម្លេងឆ្នោតគាំទ្រស្មើគ្នាក្នុងពេលបោះឆ្នោតនោះ ការបោះឆ្នោតត្រូវធ្វើឡើងសារជាថ្មីរវាងបេក្ខជន ឬបេក្ខនារីដែលទទួលបានសម្លេងឆ្នោតគាំទ្រស្មើគ្នា។

ប្រសិនបើបេក្ខជន ឬបេក្ខនារីនៅតែទទួលបានសម្លេងឆ្នោតគាំទ្រស្មើគ្នាទៀតនោះ ការបោះឆ្នោតសម្រេចចុងក្រោយត្រូវធ្វើឡើងដោយសមាជិក សមាជិកានៃគណៈកម្មការបោះឆ្នោត។ ក្នុងករណីនេះប្រសិនបើបេក្ខជន ឬបេក្ខនារីនៅតែទទួលបានសម្លេងឆ្នោតគាំទ្រស្មើគ្នាទៀតនោះសម្លេងឆ្នោតរបស់ប្រធានគណៈកម្មការបោះឆ្នោតត្រូវមានឧត្តមានុភាព។

**មាត្រា ១៥**.- ការបោះឆ្នោតត្រូវរៀបចំធ្វើឡើងដោយគណៈកម្មការបោះឆ្នោត។
គណៈកម្មការបោះឆ្នោតមានសមជិក-សមាជិកាស្ម័គ្រចិត្ត០៥រូប
ដែលត្រូវទទួលការយល់ព្រមពីអង្គសន្និបាតជាមុន។

**មាត្រា ១៦**.- ប្រធានគណៈកម្មាធិការនាយកដែលទើបជាប់ឆ្នោតថ្មី ត្រូវរៀបចំសមាសភាពគណៈកម្មាធិការនាយកដោយអនុលោមតាមមាត្រា៩ និងមាត្រា១០នៃលក្ខន្តិកៈនេះ។

**មាត្រា ១៧**.- ប្រធាន ស.អ.ន.ខ.ជ គឺជាតំណាងស្របច្បាប់របស់ ស.អ.ន.ខ.ជ ដែលមានតួនាទីគ្រប់គ្រងចាត់ចែង និងសម្រេចលើរាល់សកម្មភាពរបស់សមាគមដោយអនុលោមតាមគោលបំណងដែលបានចែងក្នុងមាត្រា៣។

**មាត្រា ១៨**.- អនុប្រធានជាជំនួយការរបស់ប្រធាន ដែលមានតួនាទីបំពេញភារកិច្ចតាមការប្រគល់សិទ្ធិរបស់ប្រធាន ស.អ.ន.ខ.ជ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ទទួលបន្ទុកបូកសរុប តាមដានចាត់ចែងភារកិច្ចទូទៅរបស់ ស.អ.ន.ខ.ជ តាមការណែនាំ និងប្រគល់របស់ប្រធាន។

ផ្នែករដ្ឋបាលទទួលបន្ទុកគ្រប់គ្រង និងចរាចរាល់លិខិតរដ្ឋបាលរបស់ ស.អ.ន.ខ.ជ។

ផ្នែកហិរញ្ញវត្ថុទទួលបន្ទុកកាន់បញ្ជីចំណូល ចំណាយរបស់ ស.អ.ន.ខ.ជ។

ផ្នែកទំនាក់ទំនង និងវប្បធម៌ទទួលខុសត្រូវផ្នែកវប្បធម៌ កីឡា និងទំនាក់ទំនងសាធារណៈរបស់ ស.អ.ន.ខ.ជ ។

ផ្នែកនិពន្ធទទួលបន្ទុករៀបចំ ចងក្រង និងបោះផ្សាយអត្ថបទនានាដែលទទួលបានការអនុម័តពីគណៈកម្មាធិការនាយករបស់ ស.អ.ន.ខ.ជ ។

ផ្នែកព័ត៌មានវិទ្យាទទួលបន្ទុកគ្រប់គ្រងគេហទំព័រ និងកិច្ចការព័ត៌មានវិទ្យារបស់ ស.អ.ន.ខ.ជ។

**មាត្រា ១៩**.- គណៈកម្មាធិការនាយកមានសមត្ថកិច្ចសម្រេចលើកិច្ចការ ដែលមានចែងក្នុងលក្ខន្តិកៈនេះ និងកិច្ចការទូទៅរបស់សមាគមដែលមានចែងក្នុងមាត្រា៣ ព្រមទាំងអនុវត្តរាល់សេចក្តីសម្រេច ឬតាមសំណូមពររបស់អង្គសន្និបាត។

**មាត្រា ២០**.- គណៈកម្មាធិការនាយកត្រូវប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬតាមសំណូមពរ២/៣នៃសមាជិក សមាជិកាគណៈកម្មាធិការនាយក។ របៀបវារៈនៃកិច្ចប្រជុំត្រូវផ្ញើរជូនគ្រប់សមាជិក សមាជិកានៃគណៈកម្មាធិការនាយកឲ្យបានមុន១(មួយ)ថ្ងៃយ៉ាងតិច។

**មាត្រា ២១**.- រាល់សេចក្តីសម្រេចរបស់គណៈកម្មាធិការនាយកនឹងចាត់ទុកជាបានការលុះត្រាតែមានសម្លេងគាំទ្រលើសពី៥០ភាគរយ នៃសមាជិក សមាជិកាដែលបានចូលរួមប្រជុំ។ សម្លេងប្រធានមានឧត្តមភាពនៅពេលដែលមានសម្លេងស្មើគ្នាលើប្រធានបទណាមួយ។

**មាត្រា ២២**.-ក្នុងករណីដែលប្រធានសុំលាលែងពីតំណែង ឬមិនអាចបំពេញភារកិច្ចបានដោយបញ្ហាសុខភាព ឬទទួលមរណភាពមុនចប់អាណត្តិរយៈពេលលើសពីមួយឆ្នាំ គណៈកម្មាធិការនាយកត្រូវរៀបចំសន្និបាតដើម្បីបោះឆ្នោតជ្រើសរើសប្រធានថ្មី សម្រាប់អាណត្តិដែលនៅសល់។ ក្នុងករណី

ដែលអាណត្តិនៅសល់មានរយៈពេលតិចជាងមួយឆ្នាំ គណៈកម្មាធិការនាយកត្រូវបោះឆ្នោតជ្រើសរើសសមាជិក សមាជិកាគណៈកម្មាធិការនាយកណាម្នាក់ធ្វើជាប្រធានស្តីទីរហូតដល់ចប់អាណត្តិ។

**មាត្រា ២៣**.- សិទ្ធិ ភារកិច្ច និងតួនាទីរបស់សមាជិក សមាជិកាម្នាក់ៗនៃគណៈកម្មាធិការនាយកនឹងត្រូវកំណត់ដោយការប្រជុំផ្ទៃក្នុងរបស់គណៈកម្មាធិការនាយក។

**មាត្រា ២៤**.- ស.អ.ន.ខ.ជ មានសិទ្ធិជ្រើសរើសបុគ្គលិកមកបម្រើការងារតាមការចាំបាច់។ បុគ្គលិកដែលត្រូវបានជ្រើសរើស ត្រូវគោរពតាមលក្ខន្តិកៈនិងគោលការណ៍នានារបស់ស.អ.ន.ខ.ជ។

## ជំពូកទី៤
## អង្គសន្និបាត

**មាត្រា ២៥**.- អង្គសន្និបាតរបស់សមាគមមានពីរប្រភេទគឺ អង្គសន្និបាតសាមញ្ញ និងវិសាមញ្ញ។ សេចក្តីសម្រេចរបស់អង្គសន្និបាតជាសេចក្តីសម្រេចខ្ពស់បំផុតរបស់ ស.អ.ន.ខ.ជ។

**មាត្រា ២៦**.- អង្គសន្និបាតសាមញ្ញ គឺជាការប្រជុំធំនៃសមាជិក សមាជិកាស្ថាបនិក និង/ឬសមាជិក សមាជិកាសកម្ម និងសមាជិក សមាជិកាធម្មតាជារៀងរាល់ឆ្នាំនៅខែធ្នូ។ អគ្គលេខាធិការត្រូវជូនដំណឹងជាសាធារណៈឱ្យបានរយៈពេល ១៥ ថ្ងៃ មុនថ្ងៃអង្គសន្និបាតដោយមានបញ្ជាក់អំពីរបៀបវារៈផង។

ប្រធាន ស.អ.ន.ខ.ជ ជាអធិបតីនៃអង្គសន្និបាត និងត្រូវធ្វើរបាយការណ៍ស្តីពីសម្មភាពរបស់ ស.អ.ន.ខ.ជ។

ប្រធានផ្នែកហិរញ្ញវត្ថុត្រូវធ្វើរបាយការណ៍អំពីចំណូល-ចំណាយ ដើម្បីដាក់ជូនអង្គសន្និបាតពិនិត្យ។

**មាត្រ ២៧**.- អង្គសន្និបាតវិសាមញ្ញអាចធ្វើឡើងបានគ្រប់ពេលវេលាតាមការចាំបាច់ ដោយមានការស្នើសុំរបស់ប្រធាន ស.អ.ន.ខ.ជ ឬសមាជិក សមាជិកាគណៈកម្មាធិការនាយក ចាប់ពីចំនួន២/៣។

អគ្គលេខាធិការត្រូវជូនដំណឹងជាសាធារណៈអោយបានរយៈពេល ០៧ ថ្ងៃ មុនថ្ងៃរៀបចំអង្គសន្និបាតវិសាមញ្ញដោយមានបញ្ជាក់អំពីរបៀបវារៈជាមួយផង។

**មាត្រា ២៨**.- សេចក្តីសម្រេចអង្គសន្និបាតអាចយកជាការបានលុះត្រាតែមានសម្លេងគាំទ្រ ចាប់ពី៥០ភាគរយបូក១ នៃសមាជិក សមាជិកាដែលមានវត្តមានក្នុងអង្គសន្និបាត។

## ជំពូកទី ៥
## ប្រភពធនធាន

**មាត្រា ២៩**.- ប្រភពធនធានរបស់ ស.អ.ន.ខ.ជ មានដូចខាងក្រោមៈ

- ប្រាក់វិភាគទានដោយស្ម័គ្រចិត្តរបស់សមាជិក សមាជិកាគ្រប់ប្រភេទ
- អំណោយរបស់សប្បុរសជនជារូបវ័ន្តបុគ្គល និងនីតិបុគ្គលដូចជាក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា

**មាត្រា ៣០.-** ដើម្បីថែរក្សាភាពអព្យាក្រឹត្យ និងឯករាជ្យរបស់ខ្លួន ស.អ.ន.ខ.ជ មិនទទួលអំណោយពីគណបក្សនយោបាយណាមួយឡើយ។

**មាត្រា ៣១.-** មូលនិធិទាំងអស់របស់ ស.អ.ន.ខ.ជ ត្រូវប្រើប្រាស់សម្រាប់បម្រើឱ្យគោលបំណង និង សកម្មភាពរបស់ ស.អ.ន.ខ.ជ តែប៉ុណ្ណោះ។

ប្រធាន ស.អ.ន.ខ.ជ ជាអ្នកបញ្ជាចំណាយលើគ្រប់មុខចំណាយរបស់ ស.អ.ន.ខ.ជ។ រាល់ការចំណាយត្រូវមានវិក្កយបត្រ និងសក្ខីប័ត្រចំណាយត្រឹមត្រូវ។

ក្នុងករណីមានភាពមិនច្បាស់ពីបញ្ហាហិរញ្ញវត្ថុ សមាជិក សមាជិកាយ៉ាងតិច ១/៣ នៃគណៈកម្មាធិការនាយកអាចសុំឱ្យមានការបំភ្លឺពីប្រធាន ស.អ.ន.ខ.ជ។

វិធាន និងនីតិវិធីលម្អិតស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ស.អ.ន.ខ.ជ ត្រូវកំណត់ដោយគណៈកម្មាធិការនាយករបស់ ស.អ.ន.ខ.ជ។

## <u>ជំពូកទី៦</u>

## បទបញ្ជាផ្ទៃក្នុង

**មាត្រា ៣២.-** គណៈកម្មាធិការនាយករបស់ ស.អ.ន.ខ.ជ ត្រូវរៀបចំតាក់តែងបទបញ្ជាផ្ទៃក្នុងដែលបញ្ជាក់ពីនីតិវិធី និងវិធានការគ្រប់គ្រងរដ្ឋបាលរបស់ ស.អ.ន.ខ.ជ។

## <u>ជំពូកទី៧</u>

## វិសោធនកម្ម និងការរំលាយ

**មាត្រា ៣៣.-** វិសោធនកម្មលើមាត្រាទាំងឡាយនៃលក្ខន្តិកៈរបស់ ស.អ.ន.ខ.ជ អាចធ្វើបានលុះត្រាតែមានសំណើពីប្រធាន ស.អ.ន.ខ.ជ ឬពីសមាជិក សមាជិកាគណៈកម្មាធិការនាយកចំនួន ២/៣ និងត្រូវបានអនុម័តយល់ព្រមដោយសម្លេងភាគច្រើនចាប់ពី ៥០ភាគរយបូក១ នៃចំនួនសមាជិក សមាជិកាដែលមានវត្តមានក្នុងអង្គសន្និបាត។

**មាត្រា ៣៤.-** ស.អ.ន.ខ.ជ អាចត្រូវរំលាយប្រសិនមានសំណើពីសមាជិក សមាជិកា ចំនួន ២/៣ និងត្រូវបានអនុម័តយល់ព្រមដោយសម្លេងយ៉ាងតិច ២/៣ នៃចំនួនសមាជិក សមាជិកា ដែលមានវត្តមានក្នុងអង្គសន្និបាត។ ក្នុងករណីនេះទ្រព្យសម្បត្តិដែលនៅសល់ក្រោយការទូទាត់បំណុលរបស់ ស.អ.ន.ខ.ជ ត្រូវប្រគល់ឱ្យអង្គការ ឬសមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុកណាមួយដែលមានគោលបំណង និងទិសដៅប្រហាក់ប្រហែលនឹងស.អ.ន.ខ.ជ តាមការសម្រេចរបស់អង្គសន្និបាត។ ប្រសិនបើមានបំណុលរបស់ ស.អ.ន.ខ.ជ ដែលនៅសេសសល់ជាបន្ទុករបស់គណៈកម្មាធិការនាយកអាណត្តិចុងក្រោយ។



JAC
JAPAN ALUMNI OF CAMBODIA

## **ជំពូកទី ៨**

## **អវសានប្បញ្ញត្តិ**

**មាត្រា ៣៥**.- លក្ខន្តិកៈនេះត្រូវបានធ្វើវិសោធនកម្ម និងអនុម័តយល់ព្រមដោយអង្គសន្និបាតកាលពីថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១០។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងលក្ខន្តិកៈនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣៦**.- លក្ខន្តិកៈនេះត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១១

**ជ.គណៈកម្មាធិការនាយក**

**ប្រធាន**

JAPAN ALUMNI OF CAMBODIA

JAC

**ហេង សួរ**

# ឧបសម្ព័ន្ធ

## នៃលក្ខន្តិកៈរបស់សមាគមអតីតនិស្សិតខ្មែរពីប្រទេសជប៉ុន

សមាគមអតីតនិស្សិតខ្មែរពីប្រទេសជប៉ុន

Japan Alumni of Cambodia

ស.អ.ន.ខ.ជ

JAC